# អង្គការជនពិការកម្ពុជា



# គោលការណ៍សមាជិកភាព

ព្រាង

ឆ្នាំ២០១២

# មាតិកា


១. សេចក្តីផ្តើម ........ 1

២. គោលបំណងនិងនិយមន័យ ........ 1

២-១ និយមន័យ ........ 1

២-២គោលបំណង ........ 1

៣. អត្ថប្រយោជន៍របស់សមាជិកភាព ........ 2

៣-១ សិទ្ធិរបស់សមាជិកពេញសិទ្ធិ ........ 2

៣-២ កិច្ចប្រជុំសមាជិកភាព ........ 2

៤. លក្ខខណ្ឌសម្រាប់ចូលជាសមាជិកភាព ........ 2

៥. ដំណើរការនិងនីតិវិធីនៃដាក់ពាក្យសមាជិកភាព ........ 3

៥.១ ពាក្យសុំចូលជាសមាជិកភាព ........ 3

៥.២ បុរេពិនិត្យលើពាក្យសុំចូលជាសមាជិកភាព ........ 3

៦. គណកម្មការពិនិត្យសមាជិកភាព ........ 4

៧. ការបញ្ឈប់សមាជិកភាព ........ 4

៧.១ ការលាឈប់ពីសមាជិកភាពដោយសមាជិក ........ 4

៧.២ ការបញ្ឈប់សមាជិកភាពដោយគណកម្មការពិនិត្យសមាជិកភាព ........ 5

៨. ការបង់ថ្លៃសមាជិកភាព ........ 5

៩. ទិន្នន័យសមាជិកភាព ........ 5

១០. សុពលភាព ........ 5

ឧបសម្ព័ន្ធ: ........ 6

កទំរង់ពាក្យសុំចូលជាសមាជិកភាព . ........ 6

ខទំរង់បុរេពិនិត្យលើពាក្យសុំចូលជាសមាជិកភាព . ........ 6

គលក្ខខណ្ឌប្រតិបត្តិសំរាប់គណកម្មការពិនិត្យសមាជិកភាព . ........ 6

ឃលិខិតបញ្ជាក់សមាជិកភាព........ 6

ងលិខិតបញ្ឈប់សមាជិកភាព . ........ 6

ចបញ្ជីទិន្នន័យសមាជិកភាព . ........ 6

# គោលការណ៍សមាជិកភាព

## ១. សេចក្តីផ្តើម

អង្គការជនពិការកម្ពុជា គឺជាអង្គការតំណាងសំលេងអង្គការតំណាងជនពិការ សមាគម សហព័ន្ធ វេទិកាស្ត្រី និងកុមារពិការតាមបណ្តាលខេត្តនានាទូទាំងប្រទេសកម្ពុជា (*លក្ខន្តិកៈប្រការទី៦*)។ ទស្សនវិស័យជនរបស់អង្គការជនពិការកម្ពុជា គឺជនពិការនៅក្នុងប្រទេសកម្ពុជាទាំងអស់មានសិទ្ធិចូលរួមដោយពេញលេញ និងសមភាពនៅក្នុងសង្គម (*លក្ខន្តិកៈប្រការទី៥*)។

អង្គការជនពិការកម្ពុជាបង្កើតឡើង ដើម្បីអភិវឌ្ឍបណ្តាញរបស់ជនពិការ ដើម្បីគាំទ្រ ការពារ បំរើ និងជំរុញនូវសិទ្ធិ សមិទ្ធផល និងផល ប្រយោជន៍នៃជនពិការ ឱ្យសម្រេចនូវគោលដៅ ដើម្បីឱ្យជនពិការមានឱកាសជាសមភាពនៅក្នុង សង្គម(លក្ខន្តិកៈប្រការ៥ )។

## ២. គោលបំណងនិងនិយមន័យ

### ២-១ និយមន័យ

សមាជិកភាព មានន័យថា ជាសមាជិកពេញសិទ្ធិដែលបានបំពេញបែបបទ ត្រឹមត្រូវ និងមានការទទួលស្គាល់ពីអង្គការជនពិការកម្ពុជា ហើយមានសិទ្ធិចូលរួមបោះឆ្នោត និងឈរឈ្មោះឱ្យគេបោះឆ្នោតជាក្រុមប្រឹក្សាភិបាលនៃអង្គការជនពិការកម្ពុជាបាន (*លក្ខន្តិកៈប្រការ៧-ខ*)។

លក្ខខណ្ឌដែលអាចចូលជាសមាជិករបស់អ.ព.ក មានចែងក្នុងជំពូកទី៤។

### ២-២គោលបំណង

គោលការណ៍សមាជិកភាពនេះត្រូវបានបង្កើតឡើងក្នុងគោលបំណង៖

- ជួយសម្របសម្រួលដល់អង្គការតំណាងជនពិការសហពន្ធ័ សមាគម វេទិកាស្ត្រី និងកុមារពិការតាមបណ្តាខេត្តនានាទូទាំងប្រទេសកម្ពុជា ឲ្យចូលរួមលើកស្ទួយគាំទ្រ និងការពារនូវសិទ្ធិ និងផលប្រយោជន៍នានារបស់ជនពិការ តាមរយៈការលើកសំលេងរួមតែមួយនៅថ្នាក់ជាតិ ដើម្បីរួមសហការជាមួយស្ថាប័នរាជរដ្ឋាភិបាល អង្គការជាតិ អន្តរជាតិនានា ស្ថាប័នឯកជន ដើម្បីផ្តល់នូវការគាំទ្រនានាផ្នែកការអភិវឌ្ឍ និងសេវាកម្មដល់ជនពិការ។
- ចូលរួមចំណែកកសាងផែនការយុទ្ធសាស្រ្តអភិវឌ្ឍនានារបស់អង្គការជនពិការកម្ពុជា
- លើកស្ទួយអភិបាលកិច្ចល្អ និងគណនេយ្យភាពដល់សមាជិក ដើម្បីធានាឲ្យមាននិរន្តភាពទាំងផ្នែកស្ថាប័ន និងហិរញ្ញវត្ថុ។

# ៣. អត្ថប្រយោជន៍របស់សមាជិកភាព

## ៣-១ សិទ្ធិរបស់សមាជិកពេញសិទ្ធិ

- សមាជិកពេញសិទ្ធិមានសិទ្ធិ(*លក្ខន្តិកៈ ប្រការ៧-ខ*)។
- ចូលរួមក្នុងមហាសន្និបាតរបស់អង្គការជនពិការកម្ពុជា។
- ចូលរួមក្នុងសកម្មភាពនានា ដែលរៀបចំឡើងដោយ អ.ព.កដែលបង្កើតឡើងដើម្បីភាពជឿនលឿននៃកម្មវិធី អ.ព.ក។
- បោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាភិបាល អ.ព.ក។
- ឈរឈ្មោះឱ្យគេបោះឆ្នោតជាក្រុមប្រឹក្សាភិបាល អ.ព.ក។
- ចូលរួមកសាងផែនការអភិវឌ្ឍនានារបស់ អ.ព.ក អំពីបញ្ហាពិការភាពសម្រាប់ជនពិការក្នុងព្រះរាជាណាចក្រកម្ពុជា។
- មានសិទ្ធិទទួលបានការសម្របសម្រួលថវិកាជំនួយ ពីម្ចាស់ជំនួយតាមរយៈអង្គការជនពិការកម្ពុជា។
- មានសិទ្ធិជាអាទិភាពទទួលបានការកសាងសមត្ថភាព ការបណ្តុះបណ្តាល ការបង្ហាត់បង្ហាញនូវជំនាញនានាពីអង្គការជនពិការកម្ពុជា។

## ៣-២ កិច្ចប្រជុំសមាជិកភាព

- សមាជិកទាំងអស់ចូលរួមប្រជុំសមាជិកភាពជាទៀងទាត់ តាមការកំណត់ជាមួយអង្គការជនពិការកម្ពុជាជារៀងរាល់ ២ខែម្តង។
- សមាជិកទាំងអស់ចែករំលែកពត៌មាន ដល់សមាជិកដទៃទៀតទាក់ទងនឹងសកម្មភាពនានា រួមទាំងករណីរំលោភសិទ្ធិជនពិការដែលកើតមាននៅក្នុងតំបន់របស់ខ្លួន។
- សមាជិកទាំងអស់និងទទួលពត៌មានពី អ.ព.ក នូវសកម្មភាពនានា បញ្ហាជនពិការ បញ្ហាច្បាប់។

# ៤. លក្ខខណ្ឌសម្រាប់ចូលជាសមាជិកភាព

អង្គការតំណាងជនពិការ សមាគម សហព័ន្ធ វេទិកាស្ត្រីនិងកុមារពិការ ដែលមានបំណង
ចូលជាសមាជិកភាពរបស់អង្គការជនពិការកម្ពុជាត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោមនេះ៖

១- ក្រុមប្រឹក្សាភិបាលជាជនពិការ

២- នាយកប្រតិបត្តិជាជនពិការ

៣- បុគ្គលិក<u>ជាជនពិការយ៉ាងហោចណាស់ ៨០%</u>

៤- មានលក្ខន្តិកៈអង្គការ សមាគម សហព័ន្ធ វេទិកាស្ត្រី ដែលបានអនុម័តដោយ ក្រុមប្រឹក្សាភិបាល

៥- មានការទទួលស្គាល់ពីអាជ្ញាធរមូលដ្ឋាន ឬក្រសួងមហាផ្ទៃ

៦- មានគោលការណ៍គ្រប់គ្រងបុគ្គលិកនិងគណនេយ្យ

៧- ត្រូវមានសមាជិករបស់ខ្លួនជាសហព័ន្ធឬក្រុមជួយខ្លួនឯងច្បាស់លាស់

# ៥. ដំណើរការនិងនីតិវិធីនៃដាក់ពាក្យសមាជិកភាព

## ៥.១ ពាក្យសុំចូលជាសមាជិកភាព

អង្គការតំណាងជនពិការ សមាគម សហព័ន្ធ វេទិកាស្ត្រីនិងកុមារពិការ ដែលមានបំណងចូលជាសមាជិកភាពរបស់អង្គការជនពិការកម្ពុជា ត្រូវបំពេញពាក្យស្នើសុំ និងឯកសារនានា រួចដាក់ជូនមកអង្គការជនពិការកម្ពុជាដើម្បីពិនិត្យ និងអនុម័តលើពាក្យស្នើសុំនោះ។ ពាក្យសុំចូលជាសមាជិកភាពមាននៅការិយាល័យអង្គការជនពិការកម្ពុជា។

ឯកសារដែលត្រូវដាក់មកអង្គការជនពិការកម្ពុជា មានៈ

១- ពាក្យសុំចូលជាសមាជិកភាព

២.លិខិតទទួលស្គាល់ដោយអាជ្ញាធរមូលដ្ឋានភូមិឃុំស្រុកខេត្ត ឬចុះបញ្ជីជាមួយក្រសួងមហាផ្ទៃ

៣. លក្ខន្តិកៈអង្គការចំនួន១ច្បាប់

៤. គោលការណ៍បុគ្គលិកនិងគណនេយ្យ

៥. បញ្ជីឈ្មោះនិងទិន្នន័យជនពិការជាសមាជិករបស់អង្គភាពខ្លួន

## ៥.២ បុរេពិនិត្យលើពាក្យសុំចូលជាសមាជិកភាព

- ពាក្យសុំចូលជាសមាជិកភាពត្រូវបានពិនិត្យជាដំបូងដោយ***មន្ត្រីសំរបសំរួលកម្មវិធី***។
- ពាក្យសុំចូលជាសមាជិកភាពដែលត្រូវបានបំពេញឯកសារត្រឹមត្រូវ ទៅតាមលក្ខខណ្ឌដូចមានក្នុងចំនុច៥.១ ហើយនោះពាក្យសុំចូលជាសមាជិកភាព នឹងត្រូវបញ្ជូនទៅគណកម្មការពិនិត្យសមាជិកភាពដើម្បីពិនិត្យនិងអនុម័ត។
- ពាក្យសុំចូលជាសមាជិកភាព ដែលមិនទាន់ត្រូវបានបំពេញឯកសារត្រឹមត្រូវទៅតាមលក្ខខណ្ឌដូចមានក្នុងចំនុច៥.១ ហើយនោះពាក្យសុំចូលជាសមាជិកភាពនឹងត្រូវបញ្ជូនទៅអង្គការដែលដាក់ពាក្យវិញ ដើម្បីបំពេញឯកសារត្រូវការបន្ថែមនិងដាក់ ពាក្យសុំចូលសមាជិកភាពឡើងវិញ។

## ៦. គណកម្មការពិនិត្យសមាជិកភាព

គណកម្មការពិនិត្យសមាជិកភាពត្រូវបានបង្កើតឡើង ដើម្បីពិនិត្យ និងផ្តល់ការអនុម័ត ដល់អង្គការតំណាងជនពិការ សមាគម សហព័ន្ធ វេទិកាស្ត្រីនិងកុមារពិការ អោយចូលជាសមាជិករបស់អង្គការជនពិការកម្ពុជា។

សមាសភាពរបស់គណកម្មការពិនិត្យសមាជិកភាពរួមមាន៖

១. ប្រធានក្រុមប្រឹក្សាភិបាល

២. អនុប្រធានក្រុមប្រឹក្សាភិបាល

៣. នាយកប្រតិបត្តិអ.ព.ក

៤. ប្រធានគ្រប់គ្រងរដ្ឋបាលនិងហិរញ្ញវត្ថុ

៥. ប្រធានគ្រប់គ្រងកម្មវិធី

លក្ខខណ្ឌប្រតិបត្តិសំរាប់គណកម្មការពិនិត្យសមាជិកភាពត្រូវបានបង្កើតឡើង ដើម្បីពិពណ៌នាពីតួនាទីទទួលខុសត្រូវរបស់គណកម្មការពិនិត្យសមាជិកភាព។

នៅពេលគណកម្មការពិនិត្យសមាជិកភាព អនុម័តលើពាក្យស្នើសុំអង្គការជនពិការកម្ពុជានឹងចេញលិខិតបញ្ជាក់សមាជិកភាពដល់អង្គការដែលដាក់ពាក្យ។

ក្នុងករណីពាក្យសុំចូលជាសមាជិកភាព មិនត្រូវបានអនុម័តដោយគណៈកម្មការពិនិត្យសមាជិកភាពពាក្យសុំចូលជាសមាជិកភាពនឹងត្រូវបញ្ជូនទៅសាមីអង្គការវិញ ដើម្បីដាក់ពាក្យសាជាថ្មីឡើងវិញក្នុងរយៈពេល២ខែ។

## ៧. ការបញ្ឈប់សមាជិកភាព

ការបញ្ឈប់សមាជិកភាពមាន ២ប្រភេទ គឺ៖

១. ការលាឈប់ពីសមាជិកភាពដោយសមាជិក

២. ការបញ្ឈប់សមាជិកភាពដោយគណៈកម្មការពិនិត្យសមាជិកភាព

### ៧.១ ការលាឈប់ពីសមាជិកភាពដោយសមាជិក

សមាជិកអាចលាឈប់ពីសមាជិកភាពអង្គការជនពិការកម្ពុជា នៅពេលណាមួយបាន ដោយសមាជិកត្រូវដាក់ពាក្យជាលាយលក្ខណ៍អក្សរជាផ្លូវការមក នាយកប្រតិបត្តិអង្គការជនពិការកម្ពុជាអោយបានបីខែមុន។

សេចក្តីសំរេចលើការទទួលពាក្យលាឈប់សមាជិកភាព នឹងលុបឈ្មោះចេញពីបញ្ជីសមាជិកភាពត្រូវធ្វើឡើងដោយគណៈកម្មការពិនិត្យសមាជិកភាព។ នាយកប្រតិបត្តិអង្គការជនពិការកម្ពុជានឹងចេញលិខិតជាផ្លូវការបញ្ជាក់ពីការលាឈប់របស់សមាជិកដល់សាមីអង្គការ។

## ៧.២ ការបញ្ឈប់សមាជិកភាពដោយគណៈកម្មការពិនិត្យសមាជិកភាព

ការបញ្ឈប់សមាជិកភាពដោយគណៈកម្មការពិនិត្យសមាជិកភាព អាចធ្វើទៅបានដរាបណាសមាជិកទាំងឡាយណា បានប្រព្រឹត្តនូវលក្ខខណ្ឌខាងក្រោមនេះចាប់ពី២ឡើងទៅ៖

១. ការអវត្តមានក្នុងកិច្ចប្រជុំច្រើនជាង៥០%ឡើងទៅ

២.ការផ្លាស់ប្តូរសមាសភាពក្រុមប្រឹក្សាភិបាលជាជនពិការមកជាជនមិនពិការ

៣- នាយកប្រតិបត្តិជាជនមិនពិការ

៤-មិនបានបង់ប្រាក់សមាជិកភាពតាមកាលកំណត់

នាយកប្រតិបត្តិអង្គការជនពិការកម្ពុជា នឹងធ្វើការលិខិតអញ្ជើញដល់សមាជិកដើម្បីធ្វើការដោះស្រាយបញ្ហា និងកែសំរួលបញ្ហានានាមកស្ថានភាពធម្មតាវិញ។

ក្នុងករណីដែលមិនមានការកែលំអពីសំណាក់សមាជិកដែលប្រព្រឹត្តខុសនោះទេ នាយកប្រតិបត្តិ នឹងធ្វើការរាយការណ៍ជូន គណៈកម្មការពិនិត្យសមាជិកភាព ដើម្បីពិនិត្យ និងអនុម័តបញ្ឈប់សមាជិកភាព។

នាយកប្រតិបត្តិអង្គការជនពិការកម្ពុជា នឹងចេញលិខិតជាផ្លូវការបញ្ជាក់ពីការបញ្ឈប់សមាជិកភាពដល់សាមីអង្គការ។

## ៨. ការបង់ថ្លៃសមាជិកភាព

សមាជិកទាំងអស់ នឹងបង់វិភាគទានសំរាប់សមាជិកភាពប្រចាំឆ្នាំដល់អង្គការជនពិការកម្ពុជាចំនួន ២០០,០០០រ។

ប្រាក់សមាជិកភាពត្រូវបង់នៅរៀងរាល់ដើមខែមករានៃឆ្នាំនីមួយៗ។

## ៩. ទិន្នន័យសមាជិកភាព

សមាជិកទាំងអស់ត្រូវរក្សាទុកក្នុងបញ្ជីទិន្នន័យសមាជិក។ បញ្ជីទិន្នន័យសមាជិក ត្រូវធ្វើបច្ចុប្បន្នភាពជាប្រចាំពេលមានសមាជិកថ្មីចុះបញ្ជី។ បញ្ជីទិន្នន័យសមាជិកភាពមានចែកដល់បុគ្គលិក អ.ព.ក តាមត្រូវការនិងផ្សព្វផ្សាយតាមគេហទំព័រ អ.ព.ក។

## ១០. សុពលភាព

គោលការណ៍សមាជិកភាពនេះមានសុពលភាពប្រើប្រាស់ចាប់ពីថ្ងៃចុះហត្ថលេខាដោយក្រុមប្រឹក្សាភិបាលអង្គការជនពិការកម្ពុជានេះតទៅ។

## ឧបសម្ព័ន្ធ៖

ក. ទំរង់ពាក្យសុំចូលជាសមាជិកភាព

ខ. ទំរង់បុរេពិនិត្យលើពាក្យសុំចូលជាសមាជិកភាព

គ. លក្ខខណ្ឌប្រតិបត្តិសំរាប់គណកម្មការពិនិត្យសមាជិកភាព

ឃ.លិខិតបញ្ជាក់សមាជិកភាព

ង. លិខិតបញ្ឈប់សមាជិកភាព

ច. បញ្ជីទិន្នន័យសមាជិកភាព